# 10 어제 도서관에서 한국어를 공부했어요

## ម្សិលមិញបានរៀនភាសាកូរ៉េនៅឯបណ្ណាល័យ

**학습 안내** ការណែនាំអំពីមេរៀន

- □ **វត្ថុបំណងមេរៀន** ការសួរនាំនិងឆ្លើយតបអំពីអាកាសធាតុនិងទីកន្លែង
- □ **វេយ្យាករណ៍** -았/었-, 에서
- □ **ពាក្យថ្មី** កាលបរិច្ឆេទនិងថ្ងៃនៅក្នុងសប្តាហ៍, ទីកន្លែងនិងសកម្មភាព
- □ **ព័ត៌មាន · វប្បធម៌** ថ្ងៃឈប់សម្រាកនៅប្រទេសកូរ៉េ

## 대화 1 ការសន្ទនា ១

Track 34

ខាងក្រោមនេះគឺជាការសន្ទនារវាងស៊ូរូនិងធូអាន់។ អ្នកទាំង២កំពុងតែសាកសួរគ្នាទៅវិញទៅមកអំពីពេលវេលាដែលបានមកដល់ក្នុងប្រទេសកូរ៉េ។ សូមស្តាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន រួចហើយចូរថាតាម។

**수루** 투안 씨는 언제 한국에 왔어요?
តើធូអាន់បានមកប្រទេសកូរ៉េតាំងពីពេលណា?

**투안** 올해 2월 10일에 한국에 왔어요. 수루 씨는 언제 한국에 왔어요?
ខ្ញុំបានមកកូរ៉េនៅថ្ងៃទី១០ ខែកុម្ភៈឆ្នាំនេះ។ ចុះស៊ូរូវិញ បានមកប្រទេសកូរ៉េតាំងតែពីពេលណា?

**수루** 저는 작년 7월에 왔어요.
ខ្ញុំបានមកតាំងតែពីខែកក្កដាឆ្នាំមុនម្ល៉េះ។

> **월, 일** ខែ, ថ្ងៃ
> នៅពេលដែលនិយាយអំពីខែយើងប្រើប្រាស់ '월' នៅពេលដែលនិយាយអំពីថ្ងៃយើងប្រើប្រាស់'일' ។
> - 오늘은 9월 7일이에요.
>   ថ្ងៃនេះជាថ្ងៃទី០៧ ខែកក្កដា។
> - 저는 4월 1일부터 회사에 가요.
>   ខ្ញុំទៅក្រុមហ៊ុនចាប់ពីថ្ងៃទី០១ខែមេសា។

> **언제** ពេលណា
> ប្រើប្រាស់នៅក្នុងប្រយោគសំណួរ ដើម្បីសាកសួរអំពីចំណុចនៃពេលវេលាណាមួយ។
> - 언제 한국어를 공부해요?
>   តើអ្នករៀនភាសាកូរ៉េនៅពេលណា?
> - 수루 씨는 언제 저녁을 먹어요?
>   តើស៊ូរូហូបអាហារថ្ងៃត្រង់នៅពេលណា?

តើអ្នកបានស្តាប់និងថាតាមការសន្ទនារួចហើយមែនដែរឬទេ? អញ្ចឹងសូមឆ្លើយសំណួរខាងក្រោម។

1. 투안 씨는 언제 한국에 왔어요? តើធូអាន់បានមកប្រទេសកូរ៉េតាំងតែពីពេលណា?
2. 수루 씨는 언제 한국에 왔어요? តើស៊ូរូបានមកប្រទេសកូរ៉េតាំងតែពីពេលណា?

정답 1. 2월 10일에 왔어요. 2. 작년 7월에 왔어요.

### 날짜 កាលបរិច្ឆេទ

| ○월<br>ខែ | 1월 | 2월 | 3월 | 4월 | 5월 | 6월 | 7월 | 8월 | 9월 | 10월 | 11월 | 12월 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 일월 | 이월 | 삼월 | 사월 | 오월 | **유월** | 칠월 | 팔월 | 구월 | **시월** | 십일월 | 십이월 |

| ○일<br>ថ្ងៃ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | 1일 | 2일 | 3일 | 4일 | 5일 | 6일 | 7일 | 8일 | 9일 | 10일 | …… |
| | 일일 | 이일 | 삼일 | 사일 | 오일 | 육일 | 칠일 | 팔일 | 구일 | 십일 | |
| | 21일 | 22일 | 23일 | 24일 | 25일 | 26일 | 27일 | 28일 | 29일 | 30일 | 31일 |
| | 이십일일 | 이십이일 | 이십삼일 | 이십사일 | 이십오일 | 이십육일 | 이십칠일 | 이십팔일 | 이십구일 | 삼십일 | 삼십일일 |

## 어휘 1 ពាក្យថ្មី ១ | 날짜와 요일 កាលបរិច្ឆេទនិងថ្ងៃនៅក្នុងសប្តាហ៍



តើថ្ងៃនេះជាថ្ងៃអ្វី?ទីប៉ុន្មាន?ហើយត្រូវនឹងខែអ្វី? យើងនឹងមកស្វែងយល់អំពីពាក្យថ្មីៗដែលនិយាយអំពីកាលបរិច្ឆេទនិងថ្ងៃនៅក្នុងសប្តាហ៍។

2020년 5월 ខែឧសភា



지난달 ខែមុន



이번 달 ខែនេះ



다음 달 ខែក្រោយ

| | | |
|---|---|---|
| 어제 ម្សិលមិញ | 오늘 ថ្ងៃនេះ | 내일 ថ្ងៃស្អែក |
| 지난주 អាទិត្យមុន | 이번 주 អាទិត្យនេះ | 다음 주 អាទិត្យក្រោយ |
| 주중 ថ្ងៃធ្វើការ (ច័ន្ទ~សុក្រ) | 주말 ថ្ងៃចុងសប្តាហ៍ | |





작년 ឆ្នាំមុន





올해 ឆ្នាំនេះ





내년 ឆ្នាំក្រោយ



សូមកុំមើលពាក្យនៅខាងលើ ហើយសាកល្បងដោះស្រាយសំណួរ។

1. 그림을 보고 〈보기〉처럼 대화를 완성하세요.

សូមមើលរូបភាព បន្ទាប់មកចូរសាកល្បងបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

2020년 3월 ខែមីនា



**보기**

가: 오늘은 무슨 요일이에요? តើថ្ងៃនេះគឺជាថ្ងៃអ្វី?

나: 수요일이에요. គឺជាថ្ងៃពុធ។

1) 가: 내일은 무슨 요일이에요?
   나: ______________________.

2) 가: 오늘은 몇 월 며칠이에요?
   나: ______________________.

3) 가: 어제는 무슨 요일이에요?
   나: ______________________.

4) 가: 이번 주 토요일은 몇 월 며칠이에요?
   나: ______________________.

**정답** 1) 목요일이에요 2) 삼월 십일이에요 3) 화요일이에요 4) 삼월 십삼일이에요

### Tip 시간 부사 គុណកិរិយាកាល

នៅខាងក្រោយគុណកិរិយាកាលតែងតែមាន '에' ភ្ជាប់នៅខាងក្រោយជានិច្ច។ ប៉ុន្តែ ពាក្យដែលមានដូចជា៖ '어제', '오늘', '내일', '올해', '언제' មិនចាំបាច់ភ្ជាប់ '에' នៅខាងក្រោយនោះទេ។

## 문법 1 វេយ្យាករណ៍ ១ | -았/었-

G10-1

យើងប្រើប្រាស់ '-았/었-' ភ្ជាប់ជាមួយកិរិយាស័ព្ទឬគុណនាម ដើម្បីប្រើប្រាស់ជាទម្រង់អតីតកាល។ មានន័យថា គឺជាការបង្ហាញអំពីសកម្មភាពអ្វីមួយដែលបានកើតឡើងរួចរាល់អស់ទៅហើយ។

| ㅏ, ㅗ → **-았어요** | ㅓ, ㅜ, ㅣ-ㅆ- → **-었어요** | 하다 → **했어요** |
|---|---|---|
| 가다 → **갔어요**<br>보다 → **봤어요** | 먹다 → 먹**었어요**<br>읽다 → 읽**었어요** | 공부하다 → 공부**했어요**<br>운동하다 → 운동**했어요** |

- 친구하고 시장에 **갔어요**. បានទៅផ្សារជាមួយមិត្តភក្តិ។
- 식당에서 점심을 **먹었어요**. បានហូបបាយថ្ងៃត្រង់នៅឯភោជនីយដ្ឋាន។
- 기숙사에서 한국어를 **공부했어요**. បានរៀនភាសាកូរ៉េនៅឯអន្តេវាសិកដ្ឋាន។



តើអ្នកបានយល់អំពីការប្រើប្រាស់ទម្រង់ជាអតីតកាលហើយមែនដែររឺទេ? អញ្ចឹងចូរសាកល្បងបញ្ចប់ប្រយោគដូច<ឧទាហរណ៍>។

2. 그림을 보고 〈보기〉처럼 대화를 완성하세요.
សូមមើលរូបភាព ហើយបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

보기


운동하다

가: 어제 뭐 했어요? តើម្សិលមិញអ្នកបានធ្វើអ្វី?
나: 운동했어요. បានហាត់ប្រាណ។

1) 
텔레비전을 보다

가: 어제 저녁에 뭐 했어요?
나: ______________________.

2) 

저녁을 먹다

가: 친구하고 뭐 했어요?
나: ______________________.

3) 
친구를 만나다

가: 일요일에 뭐 했어요?
나: ______________________.

4) 
쉬다

가: 5월 5일에 뭐 했어요?
나: ______________________.

정답 1) 텔레비전을 봤어요 2) 저녁을 먹었어요 3) 친구를 만났어요 4) 쉬었어요



រៀនថែមបន្តិចទៀតតើល្អដែរឬទេ? ចូរមើលរូបភាព ហើយបំពេញល្បះខាងក្រោមនេះដោយប្រើប្រាស់ជាទម្រង់អតីតកាលឲ្យបានត្រឹមត្រូវ។

1) 
어제 ______________.

2) 
주말에 ______________.

정답 1) 커피를 마셨어요 2) 요리했어요

## 대화 2 ការសន្ទនា ២

[redacted]



រីហាន់និងធូអាន់កំពុងតែធ្វើការសន្ទនាគ្នាអំពីអ្វីដែលពួកគេបានធ្វើនៅថ្ងៃម្សិលមិញ។ តើម្សិលមិញពួកគេបានធ្វើអ្វីខ្លះ? សូមស្ដាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន រួចហើយចូរថាតាម។

리한　투안 씨, 어제 뭐 했어요?
ធូអាន់, តើម្សិលមិញបានធ្វើអ្វី?

투안　친구하고 PC방에서 게임했어요.
리한 씨는 어제 뭐 했어요?
ខ្ញុំបានទៅលេងហ្គេមជាមួយមិត្តភក្តិនៅឯកន្លែងលេងហ្គេម។
ចុះរីហាន់វិញ ម្សិលមិញបានធ្វើអ្វីដែរ?

리한　도서관에서 한국어를 공부했어요.
ខ្ញុំបានរៀនភាសាកូរ៉េនៅឯបណ្ណាល័យ។

**하고 ជាមួយ**
ប្រើប្រាស់ដើម្បីបង្ហាញអំពីសកម្មភាពអ្វីមួយដែលធ្វើជាមួយគ្នា។ ភាគច្រើនក៏ប្រើប្រាស់ជាមួយ '같이' ដែរ។
- 저는 리한 씨하고 한국어를 배워요.
  ខ្ញុំរៀនភាសាកូរ៉េជាមួយរីហាន់។
- 동생하고 같이 저녁을 먹어요.
  ខ្ញុំហូបអាហារពេលល្ងាចជាមួយប្អូន។



តើអ្នកបានស្ដាប់និងថាតាមការសន្ទនារួចហើយមែនដែរឬទេ? អញ្ចឹងសូមឆ្លើយសំណួរខាងក្រោម។

1. 투안 씨는 어제 뭐 했어요? តើម្សិលមិញធូអាន់បានធ្វើអ្វីខ្លះ?
2. 리한 씨는 도서관에서 뭐 했어요? តើម្សិលមិញរីហាន់បានធ្វើអ្វីនៅឯបណ្ណាល័យ?

정답　1. 친구하고 PC방에서 게임했어요.　2. 한국어를 공부했어요.

### Tip '하다' 동사 កិរិយាស័ព្ទ '하다'

កន្សោមពាក្យថា៖ '게임을 했어요' អាចប្រើប្រាស់ទៅជា '게임했어요' បាន។ នៅក្នុងចំណោមកិរិយាស័ព្ទនៃភាសាកូរ៉េមានកិរិយាស័ព្ទជាច្រើនដែលប្រើប្រាស់ទម្រង់បែបនេះ។

- 공부를 하다 → 공부하다
- 노래를 하다 → 노래하다
- 전화를 하다 → 전화하다
- 요리를 하다 → 요리하다
- 운동을 하다 → 운동하다
- 쇼핑을 하다 → 쇼핑하다
- 게임을 하다 → 게임하다
- 일을 하다 → 일하다



នៅក្នុងភាសាកូរ៉េ មានកិរិយាស័ព្ទជាច្រើនដែលប្រើប្រាស់ទម្រង់ជា៖ 'នាម+을/를+하다'។ មានដូចជាពាក្យ៖ '공부를 하다', '운동을 하다', '노래를 하다', '쇼핑을 하다', '요리를 하다', '게임을 하다' ។ល។ នៅពេលដែលប្រើប្រាស់កិរិយាស័ព្ទទាំងអស់នេះ គេមិនប្រើ'을/를'នោះទេ។ ហេតុនេះហើយបានជា '공부를 하다' ក្លាយទៅជា '공부하다' វិញ។

## 어휘 2 ពាក្យថ្មី ២ | 장소와 동작 ទីកន្លែងនិងសកម្មភាព



យើងនឹងស្វែងយល់អំពីពាក្យថ្មីៗដែលនិយាយអំពីទីកន្លែងនានា។



공원
សួនច្បារសាធារណៈ



커피숍
ហាងកាហ្វេ



서점
បណ្ណាគារ



도서관
បណ្ណាល័យ



백화점
ផ្សារទំនើប



노래방
ហាងខារ៉ាអូខេ



PC방
កន្លែងលេងហ្គេម



영화관(극장)
រោងភាពយន្ត



산책하다
ដើរលំហែអារម្មណ៍



친구를 만나다
ជួបមិត្តភក្តិ



책을 읽다
អានសៀវភៅ



한국어를 공부하다
រៀនភាសាកូរ៉េ

- **공원**에서 **산책해요.**
  ដើរលំហែអារម្មណ៍នៅឯសួនច្បារសាធារណៈ។
- **커피숍**에서 **친구를 만나요.**
  **커피를 마셔요.**
  ជួបមិត្តភក្តិនៅឯហាងកាហ្វេ។ ផឹកកាហ្វេ។
- **서점**에서 **책을 사요.**
  ទិញសៀវភៅនៅឯបណ្ណាគារ។
- **도서관**에서 **책을 읽어요.**
  **한국어를 공부해요.**
  អានសៀវភៅនៅឯបណ្ណាល័យ។
  រៀនភាសាកូរ៉េ។
- **백화점**에서 **쇼핑해요.**
  ទិញទំនិញនៅឯផ្សារទំនើប។
- **노래방**에서 **노래해요.**
  ច្រៀងចម្រៀងនៅឯហាងខារ៉ាអូខេ។
- **PC방**에서 **게임해요.**
  លេងហ្គេមនៅឯកន្លែងលេងហ្គេម។
- **영화관**에서 **영화를 봐요.**
  មើលភាពយន្តនៅឯរោងភាពយន្ត។
- **기숙사**에서 **음식을 만들어요.**
  ធ្វើម្ហូបនៅឯអន្តេវាសិកដ្ឋាន។



쇼핑하다
ទិញទំនិញ



노래하다
ច្រៀងចម្រៀង



게임하다
លេងហ្គេម



영화를 보다
មើលភាពយន្ត



음식을 만들다
ធ្វើម្ហូប



សាករំលឹកពីពាក្យដែលបានរៀននៅខាងលើម្តងទៀត បន្ទាប់មកសូមដោះស្រាយសំណួរខាងក្រោម។

1. 그림을 보고 알맞은 단어를 연결하세요.
   សូមមើលរូបភាព បន្ទាប់មកចូរភ្ជាប់ទៅនឹងពាក្យដែលត្រឹមត្រូវ។

① 

② 

③ 

④ 

㉠ 노래방 ㉡ 커피숍 ㉢ 백화점 ㉣ 영화관

정답 ①㉡ ②㉠ ③㉣ ④㉢

## 문법 2 វេយ្យាករណ៍ ២ | 에서

G10-2

យើងប្រើប្រាស់ '에서' ភ្ជាប់នៅខាងក្រោយនាម ដើម្បីបង្ហាញអំពីសកម្មភាពដែលបានកើតឡើងនៅទីកន្លែងណាមួយ។

- 가: 어디**에서** 한국어를 공부해요? តើអ្នករៀនភាសាកូរ៉េនៅឯណា?
  나: 도서관**에서** 공부해요. រៀននៅឯបណ្ណាល័យ។
- 가: 어디**에서** 친구를 만났어요? តើអ្នកបានជួបមិត្តភក្តិនៅឯណា?
  나: 영화관**에서** 만났어요. បានជួបនៅរោងភាពយន្ត។
- 가: 백화점**에서** 쇼핑했어요? តើអ្នកបានទិញទំនិញនៅឯផ្សារទំនើបមែនដែរឬទេ?
  나: 아니요, 시장**에서** 쇼핑했어요. មិនមែនទេ, ខ្ញុំទិញទំនិញនៅផ្សារ។

### 비교해 보세요 សូមសាកល្បងធ្វើការប្រៀបធៀប

**✔ រវាង '에' ដែលបង្ហាញអំពីទីកន្លែងនិង '에서'**

'에' និង '에서' ត្រូវបានប្រើប្រាស់នៅខាងក្រោយនាមបញ្ជាក់ទីកន្លែងដូចគ្នា។ ខុសគ្នាត្រង់ថា '에' បង្ហាញអំពីទីតាំងនៃមនុស្សរឺក៏វត្ថុ ចំណែកឯ '에서' វិញ បង្ហាញអំពីសកម្មភាពនៅក្នុងទីតាំងមួយនោះ។

- 투안 씨는 한국**에** 있어요. (O)
- 투안 씨가 운동장에 축구를 해요. (X)
- 투안 씨는 한국에서 있어요. (X)
- 투안 씨가 운동장**에서** 축구를 해요. (O)



តើអ្នកបានយល់អំពីការប្រើប្រាស់ '에서' ហើយមែនដែររឺទេ? អញ្ចឹងសូមសាកល្បងបញ្ចប់ការសន្ទនាដូច <ឧទាហរណ៍>។

2. 그림을 보고 〈보기〉처럼 대화를 완성하세요.
   សូមមើលរូបភាព បន្ទាប់មកចូរបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

보기



가: 어제 뭐 했어요? តើម្សិលមិញបានធ្វើអ្វី?
나: <u>공원에서 산책했어요.</u> បានដើរលំហែអារម្មណ៍នៅឯសួនច្បារសាធារណៈ។

1) 
가: 어제 뭐 했어요?
나: ______________________.

2) 
가: 어제 뭐 했어요?
나: ______________________.

3) 
가: 어제 뭐 했어요?
나: ______________________.

4) 
가: 어제 뭐 했어요?
나: ______________________.

정답 1) 도서관에서 한국어를 공부했어요 2) 백화점에서 쇼핑했어요
3) 영화관에서 영화를 봤어요 4) 커피숍에서 친구를 만났어요

### 유용한 표현 កន្សោមពាក្យសំខាន់ៗ

**마음에 들어요.** ពេញចិត្ត

가: 이 잠바 어때요? តើអាវក្រៅមួយនេះ យ៉ាងម៉េចដែរ?
나: 정말 **마음에 들어요.** ខ្ញុំពិតជាពេញចិត្តខ្លាំងណាស់។

## 활동 សកម្មភាព

이번 달에 어디에서 무엇을 했어요? 달력을 보면서 친구에게 이야기해 주세요.
តើនៅខែនេះអ្នកបានធ្វើអ្វីនៅទីណាខ្លះ? សូមមើលទៅប្រតិទិនបណ្ដើរ ធ្វើការសន្ទនាជាមួយមិត្តភក្តិបណ្ដើរ។

**5월** ខែឧសភា

| 일요일 | 월요일 | 화요일 | 수요일 | 목요일 | 금요일 | 토요일 |
|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 |
| 5 | 6 | 7 | 8 | 9 | 10 | 11 영화관 |
| 12 | 13 | 14 | 15 | 16 오늘 | 17 | 18 |
| 19 | 20 | 21 | 22 | 23 | 24 백화점 | 25 |
| 26 | 27 | 28 | 29 | 30 | 31 | |

សូមមើលប្រតិទិនដែលនៅខាងលើ បន្ទាប់មកឆ្លើយនឹងសំណួរខាងក្រោម។

✚ 알맞은 말에 ✓하세요. សូមគូសសញ្ញា ✓ ទៅលើចម្លើយដែលត្រឹមត្រូវ។

(1) 내일은 5월 17일이에요. ថ្ងៃស្អែកគឺជាថ្ងៃទី១៧ ខែឧសភា។ ☐ 네 ☐ 아니요

(2) 이번 주 토요일에 영화를 봐요. មើលភាពយន្តនៅថ្ងៃសៅរ៍សប្តាហ៍នេះ។ ☐ 네 ☐ 아니요

(3) 주말에 백화점에서 쇼핑했어요. ទៅផ្សារទំនើបទិញទំនិញនៅថ្ងៃចុងសប្តាហ៍។ ☐ 네 ☐ 아니요

(4) 다음 주 화요일은 5월 21일이에요. សប្តាហ៍ក្រោយថ្ងៃអង្គារគឺជាថ្ងៃទី២១ ខែឧសភា។ ☐ 네 ☐ 아니요

정답 (1) 네 (2) 아니요 (3) 아니요 (4) 네

## 퀴즈 លំហាត់តេស្តសាកល្បង

✚ 다음 단어를 보고 생각나는 장소가 어디예요?
សូមមើលពាក្យខាងក្រោម រួចហើយចូរទស្សទាយថាវាជាទីកន្លែងណាដែរ?

나무 — 벤치 — 운동 — 산책 — ?

정답 공원

## 정보 ព័ត៌មាន

### 한국의 공휴일 ថ្ងៃឈប់សម្រាកនៅប្រទេសកូរ៉េ




- **신정** ថ្ងៃបុណ្យសកល
  គឺជាថ្ងៃដំបូងនៃថ្ងៃចូលឆ្នាំថ្មីដោយផ្អែកទៅតាមប្រតិទិនសុរិយគតិ។

- **설날** ពិធីបុណ្យចូលឆ្នាំថ្មីនៃប្រទេសកូរ៉េ
  វាជាពិធីបុណ្យធំមួយដែលតំណាងឲ្យពិធីបុណ្យប្រពៃណីជាតិកូរ៉េ។ វាជាថ្ងៃដែលក្រុមគ្រួសារនិងសាច់ញាតិមកជួបជុំគ្នា ដើម្បីសែនរំលឹកគុណដល់ជីដូនជីតាដែលបានចែកឋានទៅ និងជូនពរឆ្នាំថ្មីចំពោះគ្នាទៅវិញទៅមក។

- **삼일절 (3.1절)** ទិវាចលនាឯករាជ្យជាតិ១មីនា
  វាគឺជាថ្ងៃឈប់សម្រាកដែលរំលឹកដល់ថ្ងៃទី០១ ខែមីនា នៅពេលមានការទាមទារឯករាជ្យប្រឆាំងនឹងការគ្រប់គ្រងរបស់អាណានិគមជប៉ុន។

- **근로자의 날** ទិវាពលកម្ម
  វាគឺជាពិធីបុណ្យរំលឹកខួបមួយដែលត្រូវបានបង្កើតឡើងដោយដឹងអំពីសារៈសំខាន់នៃកម្លាំងពលកម្ម និងដើម្បីលើកទឹកចិត្តដល់កម្មករ។

- **어린이날** ទិវាសិទ្ធកុមារ
  វាជាថ្ងៃដែលគេប្រារព្ធឡើងដើម្បីប្រសិទ្ធិពរដល់កុមារឲ្យមានសុខភាពល្អនិងសុភមង្គល។

- **석가탄신일** បុណ្យវិសាខបូជា
  ជាថ្ងៃដែលព្រះពុទ្ធប្រសូត។

- **현충일** ទិវាចងចាំ
  វាគឺជាថ្ងៃដែលរំលឹកដល់ទាហាននិងប៉ូលីសដែលបានលះបង់ជីវិតរបស់ពួកគេសម្រាប់មាតុភូមិ។

- **광복절** ទិវាបុណ្យឯករាជ្យ
  វាជាថ្ងៃឈប់សម្រាកដែលរំលឹកដល់ឯករាជ្យភាពរបស់ប្រទេសកូរ៉េពីអាណានិគមជប៉ុន។

- **추석** ពិធីបុណ្យរំលឹកគុណ
  ថ្ងៃទី១៥ ខែសីហានៃច័ន្ទគតិ មានពិធីបុណ្យប្រពៃណីមួយតំណាងឲ្យប្រទេសកូរ៉េ ដែលមានឈ្មោះថា៖ 'ឈូសក'។ ពិធីបុណ្យនេះត្រូវបានប្រារព្ធឡើងដើម្បីថ្លែងអំណរគុណដល់ជីដូនជីតាចំពោះការប្រមូលផលប្រចាំឆ្នាំ។ នៅក្នុងពិធីបុណ្យនេះ គេបរិភោគនំកូរ៉េម្យ៉ាងឈ្មោះថា 'សុងផ្យ៉ន់' និងហូបផ្លែសារីជាដើម។

- **개천절** ពិធីបុណ្យនៃការកើតឡើងនៃប្រទេសកូរ៉េ
  វាជាថ្ងៃរំលឹកដល់ការបង្កើតឡើងដំបូងរបស់ប្រទេសកូរ៉េ។

- **한글날** ទិវាអក្សរកូរ៉េ
  វាជាថ្ងៃដែលរំលឹកដល់ការបង្កើតឡើងនូវ 'អក្សរកូរ៉េ' ដោយស្តេចសេចុង។

- **크리스마스** ថ្ងៃបុណ្យគ្រីស្តស្មាស
  ជាថ្ងៃដែលរំលឹកដល់ការប្រសូតរបស់ព្រះយេស៊ូ។

# EPS-TOPIK 듣기 វិញ្ញាសាស្ដាប់ EPS-TOPIK



បន្ទាប់ទៅនេះ សូមស្តាប់ដោយយកចិត្តទុកដាក់ រួចហើយចូរជ្រើសរើសយកកាលបរិច្ឆេទឲ្យបានត្រឹមត្រូវ។

[1~3] 들은 것을 고르십시오. ចូរជ្រើសរើសយកចម្លើយដែលអ្នកបានស្តាប់លឺ។

Track 36

1. ① 1월 2일 ② 1월 12일 ③ 2월 21일 ④ 2월 22일

2. ① 3월 10일 ② 3월 20일 ③ 4월 10일 ④ 4월 20일

3. ① 11월 15일 ② 11월 25일 ③ 12월 15일 ④ 12월 25일



បន្ទាប់ទៅនេះ គឺជាការជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។ មុននឹងស្តាប់សំណួរ សូមក្រឡេកមើលខ្លឹមសារនៃចម្លើយជាមុនសិន។

[4~5] 질문을 듣고 알맞은 대답을 고르십시오. សូមស្តាប់សំណួរ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

4. ① 작년에 왔어요. ② 베트남에서 왔어요.
③ 동생이 한국에 왔어요. ④ 친구하고 한국에 왔어요.

5. ① 도서관이 커요. ② 도서관에 가요.
③ 도서관에 없어요. ④ 도서관에서 공부했어요.



### 듣기 대본 អត្ថបទនៅក្នុងវិញ្ញាសាស្តាប់

1. 여: 일월 십이일 ថ្ងៃទី១២ ខែមករា
2. 남: 사월 십일 ថ្ងៃទី១០ ខែមេសា
3. 여: 십이월 이십오일 ថ្ងៃទី២៥ ខែធ្នូ
4. 남: 언제 한국에 왔어요? តើអ្នកបានមកប្រទេសកូរ៉េតាំងតែពីពេលណា?
5. 여: 어제 뭐 했어요? តើម្សិលមិញបានធ្វើអ្វី?

정답 1. ② 2. ③ 3. ④ 4. ① 5. ④

## 확장 연습 លំហាត់អនុវត្តបន្ថែម

L-10

1. 들은 것을 고르십시오. ចូរជ្រើសរើសយកចម្លើយដែលអ្នកបានស្តាប់លឺ។

① 내일은 7월 11일이에요. ② 내일은 7월 30일이에요.
③ 오늘은 7월 20일이에요. ④ 오늘은 7월 31일이에요.

2. 질문을 듣고 알맞은 대답을 고르십시오.
សូមស្តាប់សំណួរ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

① 10일이에요. ② 12월이에요.
③ 화요일이에요. ④ 5시 10분이에요.

### 확장 연습 듣기 대본 អត្ថបទស្តាប់នៅក្នុងលំហាត់អនុវត្តបន្ថែម

1. 남: 오늘은 7월 31일이에요. ថ្ងៃនេះជាថ្ងៃទី៣១ ខែកក្កដា។
2. 남: 내일이 무슨 요일이에요? តើថ្ងៃស្អែកគឺជាថ្ងៃអ្វី?

정답 1. ④ 2. ③

## 유용한 표현 កន្សោមពាក្យសំខាន់ៗ

**제 생각에도 그래요.** គំនិតខ្ញុំក៏អញ្ចឹងដែរ។

가: 회식도 회사 생활에서 중요한 것 같아요. ពិធីជប់លៀងក្រុមហ៊ុនក៏សំខាន់សម្រាប់ជីវិតការងារដែរ។
나: **제 생각에도 그래요.** គំនិតខ្ញុំក៏អញ្ចឹងដែរ។

# EPS-TOPIK 읽기 វិញ្ញាសាអាន EPS-TOPIK



សំណួរទី១ គឺជារូបភាពដែលទាក់ទងទៅនឹងទីកន្លែង ហើយសំណួរទី២វិញ គឺជារូបភាពដែលទាក់ទងទៅនឹងសកម្មភាព។ សូមជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងរូបភាព។

[1~3] 다음 그림을 보고 맞는 단어나 문장을 고르십시오.

សូមមើលរូបភាពខាងក្រោម បន្ទាប់មកចូរជ្រើសរើសយកពាក្យឬកន្សោមពាក្យដែលត្រឹមត្រូវ។

1.



① 커피숍　② 도서관
③ 노래방　④ 백화점

2.



① 쇼핑해요.　② 노래해요.
③ 공부해요.　④ 게임해요.

3.



① 책을 읽어요.　② 영화를 봐요.
③ 친구를 만나요.　④ 음식을 만들어요.



បន្ទាប់ទៅនេះ សូមជ្រើសរើសចម្លើយណាដែលត្រឹមត្រូវ ដើម្បីបំពេញចន្លោះ។ សូមរំលឹកអំពីគុណកិរិយាកាលនិងទម្រង់អតីតកាលដែលអ្នកបានរៀនរួចមកហើយនោះបណ្តើរ និងធ្វើការដោះស្រាយសំណួរបណ្តើរ។

[4~5] 빈칸에 들어갈 가장 알맞은 것을 고르십시오.

ចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

4.

가: ______________ 한국에 왔어요? តើអ្នកបានមកប្រទេសកូរ៉េតាំងពីពេលណា?
나: 작년 7월에 왔어요. ខ្ញុំបានមកប្រទេសកូរ៉េតាំងពីខែកក្កដាឆ្នាំមុន។

① 누가　② 어디　③ 무슨　④ 언제

5.

가: 어제 뭐 했어요? តើម្សិលមិញបានធ្វើអ្វី?
나: 극장에서 영화를 ______________. បានមើលភាពយន្តនៅឯរោងភាពយន្ត។

① 갔어요　② 봤어요　③ 쇼핑했어요　④ 산책했어요

정답 1. ① 2. ② 3. ③ 4. ④ 5. ②



## 확장 연습 លំហាត់អនុវត្តបន្ថែម

[1~2] 다음 그림을 보고 맞는 문장을 고르십시오.
សូមមើលរូបភាពខាងក្រោម បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

1.



① 서점　② 도서관
③ 백화점　④ 영화관

2.



① 게임을 해요.　② 산책을 해요.
③ 영화를 봐요.　④ 책을 읽어요.

[3~4] 빈칸에 들어갈 가장 알맞은 것을 고르십시오.
ចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

3.

> 저는 ________에 운동을 합니다. 토요일에는 등산을 하고 일요일에는 회사 동료들과 축구를 합니다.
> ខ្ញុំហាត់ប្រាណនៅថ្ងៃចុងសប្តាហ៍។ នៅថ្ងៃសៅរ៍ខ្ញុំឡើងភ្នំ និងនៅថ្ងៃអាទិត្យវិញ ខ្ញុំទាត់បាល់ជាមួយមិត្តរួមការងារ។

① 내년　② 어제　③ 작년　④ 주말

4.

> 가: 주말에 어디에서 쇼핑했어요? តើចុងសប្តាហ៍អ្នកបានទិញទំនិញនៅឯណា?
> 나: ____________________.

① 구두를 샀어요.　② 지난주에 샀어요.
③ 동생하고 쇼핑했어요.　④ 백화점에서 쇼핑했어요.

정답 1. ② 2. ③ 3. ④ 4. ④

## 발음 ការបញ្ចេញសម្លេង

P-03

### សូមស្តាប់ដោយយកចិត្តទុកដាក់ រួចថាតាម។

នៅក្នុងភាសាកូរ៉េមានការបញ្ចេញសម្លេងចំនួនបីគឺ៖ សម្លេងស្រាល, សម្លេងល្អម, និងសម្លេងធ្ងន់។ ចំពោះជនជាតិកូរ៉េផ្ទាល់ ㅂ, ㅃ, ㅍ ([p, p', pʰ]) ពួកគេមានភាពងាយស្រួលក្នុងការបែងចែកសម្លេងទាំងបីនេះ។ ប៉ុន្តែក្នុងនាមជាអ្នករៀនភាសាកូរ៉េវិញវាមិនងាយស្រួលនោះទេក្នុងការបែងចែកឲ្យដាច់ស្រលះរវាងសម្លេងទាំងបីនេះ។ ការបញ្ចេញសម្លេងបែបនេះ ក៏មានទៀតដែរនៅក្នុងព្យញ្ជនៈដែលមានដូចជា៖ ㄷ, ㄸ, ㅌ ([t, t', tʰ]) និង ㅈ, ㅉ, ㅊ ([ʧ, ʧ', ʧʰ]) ក៏ត្រូវបែងចែកការបញ្ចេញសម្លេងដូចគ្នានេះដែរ។

(1) ㅂ : ㅃ : ㅍ,　ㄷ : ㄸ : ㅌ,　ㄱ : ㄲ : ㅋ,　ㅈ : ㅉ : ㅊ
(2) 바 : 빠 : 파,　다 : 따 : 타,　가 : 까 : 카,　자 : 짜 : 차
(3) 보 : 뽀 : 포,　도 : 또 : 토,　고 : 꼬 : 코,　조 : 쪼 : 초
(4) 사자, 기차, 커피, 포도, 도토리, 토끼, 코끼리